# ព្រះរាជក្រម

នស/រកម/០៦១៣/០០៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការបង្ការ និងការពន្លត់អគ្គិភ័យ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៣ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

បណ្ណាគារច្បាប់កម្ពុជា www.law-society.asia Tel : 088 777 7715

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងលើកកម្ពស់ការបង្ការនិងការពន្លត់អគ្គិភ័យ សំដៅការពារអាយុជីវិត ទ្រព្យសម្បត្តិ បរិស្ថាន សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ។

**មាត្រា ២.-**

ច្បាប់នេះមានគោលដៅកំណត់អំពីការទទួលខុសត្រូវរបស់ជនគ្រប់រូប និងអំពីលក្ខខណ្ឌវិធានការនានាដើម្បីបង្ការនិងពន្លត់អគ្គិភ័យ ។

**មាត្រា ៣.-**

ច្បាប់នេះមានវិសាលភាពគ្របដណ្តប់លើរាល់សកម្មភាពបង្ការនិងពន្លត់អគ្គិភ័យ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤.-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះមាននិយមន័យដូចខាងក្រោម ៖

- **អគ្គិភ័យ** សំដៅដល់ករណីមានភ្លើងឆេះមិនអាចគ្រប់គ្រងបានដែលអាចបង្កមហន្តរាយដល់អាយុជីវិត ទ្រព្យសម្បត្តិ និងបរិស្ថាន ។
- **ការបង្ការអគ្គិភ័យ** សំដៅដល់ការរៀបចំអនុវត្តនូវលក្ខខណ្ឌ និងវិធានការនានាដើម្បីធានាសុវត្ថិភាព មិនឲ្យមានអគ្គិភ័យកើតឡើង ។
- **ប្រព័ន្ធបង្ការនិងពន្លត់អគ្គិភ័យ** សំដៅដល់ការបំពាក់ឧបករណ៍បច្ចេកទេសក្នុងនិង/ឬក្រៅគោលដៅ និងវិធានការនានាដើម្បីបង្ការទប់ស្កាត់ ពន្លត់អគ្គិភ័យ និងសង្គ្រោះ ។
- **មធ្យោបាយ** សំដៅដល់យានយន្ត ឧបករណ៍ សម្ភារៈ បរិក្ខារដែលប្រើប្រាស់សម្រាប់បង្ការនិងពន្លត់អគ្គិភ័យ ។
- **ទីកន្លែងងាយឆេះឬងាយផ្ទុះឆេះ** សំដៅដល់ទីកន្លែងដែលមានស្តុក ប្រើប្រាស់សារធាតុងាយឆេះឬងាយផ្ទុះឆេះ ។
- **សារធាតុងាយឆេះឬងាយផ្ទុះឆេះ** សំដៅដល់សារធាតុរាវ រឹង ឧស្ម័ន គីមី ទំនិញ ឬវត្ថុធាតុដើមដែលងាយឆេះឬងាយផ្ទុះឆេះ ។
- **ការពន្លត់អគ្គិភ័យ** សំដៅដល់ការពន្លត់អគ្គិភ័យនិងទប់ស្កាត់ការឆេះរាលដាលដោយប្រើប្រាស់កម្លាំង ប្រើប្រាស់មធ្យោបាយពន្លត់អគ្គិភ័យ និងប្រើប្រាស់គ្រប់វិធានការផ្សេងៗទៀត ។

- តំបន់ពន្លត់អគ្គិភ័យ សំដៅដល់ទីកន្លែងកំពុងឆេះឬប្រឡាយមនឹងការឆេះដែលសមត្ថកិច្ចកំពុងប្រតិបត្តិការពន្លត់អគ្គិភ័យ ។
- គោលដៅ សំដៅដល់ទីកន្លែងនានានិងមធ្យោបាយដឹកជញ្ជូនទាំងឡាយដែលអាចមានអគ្គិភ័យកើតឡើង ។

**មាត្រា ៥.-**

រាល់អំពើដែលអាចបង្កឲ្យមានអគ្គិភ័យកើតឡើងត្រូវហាមឃាត់ ។

**មាត្រា ៦.-**

ជនគ្រប់រូបដែលរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា មានករណីយកិច្ចចូលរួមក្នុងសកម្មភាពបង្ការនិងពន្លត់អគ្គិភ័យ ។

## ជំពូកទី ២
## សមត្ថកិច្ច

**មាត្រា ៧.-**

ក្រសួងមហាផ្ទៃមានសមត្ថកិច្ចក្នុងការស្នើនិងដាក់ចេញនូវគោលការណ៍ វិធានការ ការបណ្តុះបណ្តាល ការហ្វឹកហាត់ជំនាញអំពីការបង្ការនិងការពន្លត់អគ្គិភ័យ ។

**មាត្រា ៨.-**

អ្នកទទួលខុសត្រូវតាមគោលដៅនានា ត្រូវទទួលខុសត្រូវដោយផ្ទាល់ក្នុងកិច្ចប្រតិបត្តិការបង្ការនិងពន្លត់អគ្គិភ័យ ។

អង្គភាពនគរបាលបង្ការនិងពន្លត់អគ្គិភ័យ ត្រូវឆ្លើយតបតាមសំណើឬអន្តរាគមន៍ជាបន្ទាន់ដល់គ្រប់គោលដៅដែលមានអគ្គិភ័យកើតឡើង ។

លក្ខខណ្ឌនិងវិធានការនានាស្តីពីការបង្ការនិងការពន្លត់អគ្គិភ័យតាមគោលដៅ និងការបង្ការអគ្គិភ័យនៅតាមលំនៅឋានរបស់ជនគ្រប់រូប ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៩.-**

កិច្ចប្រតិបត្តិការបង្ការនិងពន្លត់អគ្គិភ័យ ការត្រួតពិនិត្យ ការបញ្ជាក់ទទួលស្គាល់ប្រព័ន្ធបង្ការអគ្គិភ័យលើគោលដៅ ការផ្អាកសកម្មភាពបណ្តោះអាសន្នដល់គោលដៅ ឬសកម្មភាពណាដែលខ្វះលក្ខខណ្ឌនិងវិធានការបង្ការនិងពន្លត់អគ្គិភ័យ ការពិនិត្យអង្កេតកន្លែងកើតហេតុ ការធ្វើកោសល្យវិច័យ ចំពោះជាសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃដែលមានអគ្គស្នងការដ្ឋាននគរបាលជាតិជាសេនាធិការ ។

បណ្ណាគារច្បាប់កម្ពុជា www.law-society.asia Tel : 088 777 7715

**មាត្រា ១០.-**

អ្នកទទួលខុសត្រូវតាមគោលដៅនានា ត្រូវចូលរួមជួយសង្គ្រោះនិងពន្លត់អគ្គិភ័យដែលកើតមាន ឡើងនៅជិតគោលដៅរបស់ខ្លួន លើកលែងតែនៅក្នុងមូលដ្ឋានកងទ័ពឬគោលដៅក្រោកការសម្ងាត់ទាក់ទងនឹងសន្តិសុខជាតិ ឬក្នុងស្ថានទូត ស្ថានកុងស៊ុល ស្ថានតំណាងបរទេស និវេសនដ្ឋាន ឬស្ថានតំណាងអង្គការអន្តរជាតិ ដែលត្រូវមានសំណូមពរសុំជំនួយ ។

**មាត្រា ១១.-**

គ្រប់គោលដៅ គ្រប់ប្រព័ន្ធឃោសនាត្រូវមានកម្មវិធីផ្សព្វផ្សាយអប់រំនិងលើកកម្ពស់ការយល់ដឹងអំពីវិធានការបង្ការនិងពន្លត់អគ្គិភ័យ ។

**មាត្រា ១២.-**

កិច្ចសហប្រតិបត្តិការជួយពន្លត់អគ្គិភ័យនិង/ឬសំណើសុំជំនួយពន្លត់អគ្គិភ័យជាមួយបណ្តាប្រទេស និងអង្គការអន្តរជាតិនានា ជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលដែលមានក្រសួងមហាផ្ទៃជាសេនាធិការ ។

**មាត្រា ១៣.-**

ថ្ងៃទី២២ ខែកុម្ភៈរៀងរាល់ឆ្នាំ ត្រូវបានកំណត់ជាថ្ងៃប្រារព្ធទិវាជាតិបង្ការនិងពន្លត់អគ្គិភ័យ ។

## ជំពូកទី ៣
## ការបង្ការអគ្គិភ័យ

**មាត្រា ១៤.-**

ការស្តុកទុក ការដឹកជញ្ជូន ការគ្រប់គ្រង ការលក់ ការប្រើប្រាស់សារធាតុងាយឆេះ ងាយផ្ទុះឆេះ ប្រភពភ្លើង និងប្រភពកំដៅ ដែលអាចបង្កឲ្យមានអគ្គិភ័យត្រូវអនុវត្តតាមលក្ខខណ្ឌនិងវិធានការនានាស្តីពីការបង្ការនិងការពន្លត់អគ្គិភ័យ ដែលត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្រោយមានការឯកភាពពីអាជ្ញាធរជំនាញពាក់ព័ន្ធ ។

**មាត្រា ១៥.-**

អ្នកផលិត អ្នកធ្វើពាណិជ្ជកម្ម និងអ្នកដឹកជញ្ជូនប្រេងឥន្ធនៈ សារធាតុងាយឆេះឬងាយផ្ទុះឆេះត្រូវមានវិញ្ញាបនបត្របញ្ជាក់អំពីការហ្វឹកហ្វឺនជំនាញបង្ការនិងពន្លត់អគ្គិភ័យ ។ ការហ្វឹកហ្វឺនអំពីជំនាញបង្ការនិងពន្លត់អគ្គិភ័យ និងការផ្តល់វិញ្ញាបនបត្របញ្ជាក់ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១៦.-**

ការដាក់លក់រាយប្រេងឥន្ធនៈឬឧស្ម័នចំហេះរបស់ប្រជាពលរដ្ឋ ដើម្បីបម្រើជីវភាពប្រចាំថ្ងៃ ត្រូវអនុវត្តតាមលក្ខខណ្ឌនិងវិធានការនានា ស្តីពីការបង្ការនិងការពន្លត់អគ្គិភ័យដូចមានចែងនៅក្នុងមាត្រា ១៤ នៃច្បាប់នេះ ។

**មាត្រា ១៧.-**

គោលដៅស្តុក ផលិតកែច្នៃប្រេងឥន្ធនៈ កែច្នៃសារជាតុងាយឆេះឬងាយផ្ទុះឆេះ ត្រូវស្ថិតនៅទីតាំងដែលធានាមិនបង្កហានិភ័យដល់ទីប្រជុំជន។ ចំពោះគោលដៅទាំងឡាយណាដែលមានការអនុញ្ញាតរួចហើយ ត្រូវអនុវត្តតាមលក្ខខណ្ឌនិងវិធានការនានាស្តីពីការបង្ការនិងការពន្លត់អគ្គិភ័យដូចមានចែងនៅក្នុងមាត្រា ១៤ នៃច្បាប់នេះ ។

**មាត្រា ១៨.-**

គ្រប់ទីប្រជុំជនត្រូវមានប្លង់គោលតម្កល់ទុកនៅអង្គភាពនគរបាលបង្ការនិងពន្លត់អគ្គិភ័យ ។

រាល់សំណង់ត្រូវធានាឲ្យមានប្លង់ប្រព័ន្ធបង្ការនិងពន្លត់អគ្គិភ័យមុនដំណើរការសាងសង់ ។

ចំណាត់ថ្នាក់សំណង់និងគោលដៅ ដែលតម្រូវឲ្យមានប្លង់ប្រព័ន្ធបង្ការនិងពន្លត់អគ្គិភ័យ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ។

**មាត្រា ១៩.-**

ការត្រួតពិនិត្យនិងការចេញសេចក្តីបញ្ជាក់អំពីគុណភាព ប្រសិទ្ធភាពនៃប្រព័ន្ធបង្ការនិងពន្លត់អគ្គិភ័យ ដល់គោលដៅត្រូវធ្វើឡើងសម្រាប់រយៈពេល ២ឆ្នាំម្តង ។ ក្នុងករណីចាំបាច់ ម្ចាស់គោលដៅអាចលើកសំណើសុំឲ្យត្រួតពិនិត្យមុនកាលកំណត់បាន ។

បែបបទនិងនីតិវិធីនៃការត្រួតពិនិត្យ ការចេញសេចក្តីបញ្ជាក់អំពីគុណភាព ប្រសិទ្ធភាពនៃប្រព័ន្ធបង្ការនិងពន្លត់អគ្គិភ័យ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ២០.-**

នៅគ្រប់ការរៀបចំពិធីធំៗដែលប្រមូលផ្តុំមនុស្សច្រើនកុះករ អ្នករៀបចំ ឬអ្នកគ្រប់គ្រង ឬអ្នកទទួលខុសត្រូវពិធី ត្រូវសហការជាមួយអង្គភាពនគរបាលបង្ការនិងពន្លត់អគ្គិភ័យ ដើម្បីធ្វើផែនការបង្ការពន្លត់អគ្គិភ័យនិងជម្លៀសមនុស្សចេញក្នុងករណីមានអគ្គិភ័យកើតឡើង ។

## ជំពូកទី ៤
## ការពន្លត់អគ្គិភ័យ

**មាត្រា ២១.-**

ក្នុងករណីមានអគ្គិភ័យកើតឡើង មន្ត្រីបញ្ជាដឹកនាំនគរបាលពន្លត់អគ្គិភ័យមានសិទ្ធិ ៖

- កំណត់តំបន់ប្រតិបត្តិការពន្លត់អគ្គិភ័យនិងតំបន់ហាមឃាត់ការចេញចូលឆ្លងកាត់ និងសហការការពារ សន្តិសុខ សណ្ដាប់ធ្នាប់ របៀបរៀបរយសាធារណៈ
- ប្រមូលកម្លាំងប្រជាពលរដ្ឋដែលមានអាយុចាប់ពី ១៨ឆ្នាំឡើង និងមធ្យោបាយនានាដើម្បីជួយសង្គ្រោះជីវិតមនុស្ស ទ្រព្យសម្បត្តិ និងជួយពន្លត់អគ្គិភ័យ ។

**មាត្រា ២២.-**

នៅពេលដែលមានអគ្គិភ័យកើតឡើង មន្ត្រីដឹកនាំនគរបាលប្រតិបត្តិការពន្លត់អគ្គិភ័យត្រូវចាត់វិធានការគ្រប់បែបយ៉ាងដើម្បីពន្លត់អគ្គិភ័យ សំដៅជួយសង្គ្រោះជីវិតមនុស្សនិងទ្រព្យសម្បត្តិជាបន្ទាន់ ។

**មាត្រា ២៣.-**

ជនណាដែលបានដឹងព័ត៌មានអំពីអគ្គិភ័យឬបានឃើញអគ្គិភ័យកើតឡើងឬបម្រុងនឹងកើតឡើង ត្រូវផ្ដល់ដំណឹងជាបន្ទាន់ដល់សមត្ថកិច្ចឬនគរបាលបង្ការនិងពន្លត់អគ្គិភ័យដែលនៅជិតបំផុត ដើម្បីចាត់វិធានការដោះស្រាយឲ្យបានទាន់ពេលវេលា ។

នៅពេលដែលមានអគ្គិភ័យកើតឡើង ហើយពុំទាន់មានវត្តមាននគរបាលបង្ការនិងពន្លត់អគ្គិភ័យ អ្នកទទួលខុសត្រូវតាមគោលដៅឬអាជ្ញាធរមានសមត្ថកិច្ចនៅនឹងកន្លែង ត្រូវចាត់វិធានការជាបន្ទាន់ដើម្បីជួយសង្គ្រោះជីវិតមនុស្ស ទ្រព្យសម្បត្តិ និងពន្លត់អគ្គិភ័យ ។

ក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធនានានៅពេលទទួលបានសំណូមពរសុំជួយអន្តរាគមន៍ត្រូវឆ្លើយតបជាបន្ទាន់ ។

## ជំពូកទី ៥
## ការគាំពារ

**មាត្រា ២៤.-**

ចំពោះភ្នាក់ងារនគរបាលបង្ការនិងពន្លត់អគ្គិភ័យ ឬជនណាដែលពលីជីវិតឬរងរបួស ប៉ះពាល់សុខភាព ឬពិការមួយជីវិតក្នុងពេលប្រតិបត្តិការពន្លត់អគ្គិភ័យ រដ្ឋត្រូវទទួលខុសត្រូវដោះស្រាយគោលនយោបាយ ផ្ដល់កិត្តិយស និងផ្ដល់ការព្យាបាលដោយឥតគិតថ្លៃ ។

ការផ្ដល់សំណងនៃការខូចខាតទ្រព្យសម្បត្តិ ដូចមានចែងក្នុងមាត្រា ២១ និងមាត្រា ២២ នៃច្បាប់នេះជាបន្ទុករបស់រដ្ឋ ។

**មាត្រា ២៥.-**

រដ្ឋទទួលខុសត្រូវដោះស្រាយទីកន្លែង ជម្រកស្នាក់នៅបណ្ដោះអាសន្ន និងដោះស្រាយជីវភាពសង្គមដល់ជនរងគ្រោះដោយសារអគ្គិភ័យ ។

**មាត្រា ២៦.-**

រដ្ឋលើកទឹកចិត្តសប្បុរសជន អង្គការជាតិ អង្គការអន្តរជាតិក្នុងការជួយឧបត្ថម្ភ សង្គ្រោះដល់ជនរងគ្រោះដោយសារអគ្គិភ័យ ។

## ជំពូកទី ៦
## ទោសប្បញ្ញត្តិ

**មាត្រា ២៧.-**

មន្ត្រីសមត្ថកិច្ចអគ្គិភ័យដែលខ្វះការទទួលខុសត្រូវ មិនបំពេញភារកិច្ច ឬបំពេញភារកិច្ចដោយមិនត្រឹមត្រូវក្នុងការពន្លត់អគ្គិភ័យ បង្កឲ្យមានការខូចខាតធ្ងន់ធ្ងរដល់ទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់អ្នកដទៃត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦(ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៤ ០០០ ០០០ (បួនលាន) រៀល ។

**មាត្រា ២៨.-**

អំពើរារាំង បង្កឧបសគ្គដោយចេតនា ដល់សកម្មភាពពន្លត់អគ្គិភ័យ បង្កឲ្យមានការខូចខាតធ្ងន់ធ្ងរដល់ទ្រព្យសម្បត្តិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល ។

**មាត្រា ២៩.-**

អំពើផ្តល់ព័ត៌មានក្លែងឬអំពើបើកកកាយព័ត៌មានក្លែង ដើម្បីធ្វើឲ្យជឿថាអគ្គិភ័យនឹងកើតមាន ឬអគ្គិភ័យបានកើតមានឡើង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀល ទៅ ៤ ០០០ ០០០ (បួនលាន) រៀល ។

**មាត្រា ៣០.-**

នីតិបុគ្គលអាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌចំពោះអំពើបំផ្លិចបំផ្លាញធ្វើឲ្យខូចខាតទ្រាម ឬធ្វើឲ្យខូចខាតទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិអ្នកដទៃដោយអានុភាពនៃអគ្គិភ័យ កាលបើអំពើនេះបណ្តាលមកពី ៖

បណ្ណាគារច្បាប់កម្ពុជា www.law-society.asia Tel : 088 777 7715

១- ការធ្វេសប្រហែស ការមិនប្រុងប្រយ័ត្ន ឬការខ្ជីខ្ជា ។

២- ការរំលោភបំពានលើកាតព្វកិច្ចសន្តិសុខឬកាតព្វកិច្ចប្រុងប្រយ័ត្នដែលច្បាប់តម្រូវ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥ ០០០ ០០០ (ប្រាំលាន) រៀល ទៅ ២០ ០០០ ០០០ (ម្ភៃលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើនដូចមានចែងក្នុងមាត្រា ២០៩ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ៣១.-**

ក្រៅពីបទល្មើសដែលមានចែងក្នុងច្បាប់នេះ អំពើដែលជាបទល្មើសព្រហ្មទណ្ឌត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

## ជំពូកទី ៧
## អន្តរប្បញ្ញត្តិ

**មាត្រា ៣២.-**

បទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ៨ និងពីមាត្រា ១៤ ដល់មាត្រា ១៩ ត្រូវចាប់អនុវត្តក្នុងរយៈពេល ១ (មួយ) ឆ្នាំ ក្រោយពេលច្បាប់នេះចូលជាធរមាន ។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**មាត្រា ៣៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំងថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

ចារ.១៣០៦.៥៧៩

**នរោត្តម សីហមុនី**

**បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ**

**សូមឡាយព្រះហស្តលេខា**

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**បានយកសេចក្តីគោរពជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ហត្ថលេខា**

**ស ខេង**

លេខ: ៤៦៦ ស.ណ

**សំណៅដែលមានតម្លៃជាការចេញផ្សាយ**

**រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៣**

**អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល**

**ចយ សុខា**